# ការស៊ើបអង្កេតពន្ធភេសជ្ជៈនៅទីក្រុង PHILADELPHIA ៖ អ្វីដែលរំពឹងទុក

CITY OF PHILADELPHIA
DEPARTMENT OF REVENUE

PHILLY BEV TAX IS HERE

ក្នុងនាមជាអ្នកលក់ភេសជ្ជៈផ្អែម លោកអ្នកនឹងទទួលបានការចុះពិនិត្យម្តងម្កាលដោយអ្នកស៊ើបអង្កេតពន្ធភេសជ្ជៈ។ នេះមិនមែនមានន័យថាលោកអ្នកបានធ្វើអ្វីមួយខុសឡើយ! អ្នកស៊ើបអង្កេតគ្រាន់តែចង់ធានាថាអ្នកលក់នានាអនុវត្តទៅតាមពន្ធតែប៉ុណ្ណោះ។

នេះជាដំណើរការ៖

## ការស៊ើបអង្កេត

អ្នកស៊ើបអង្កេតពន្ធភេសជ្ជៈនឹងមកដល់កន្លែងអាជីវកម្មរបស់លោកអ្នក និងស្នើសុំមើលឯកសារពន្ធភេសជ្ជៈរបស់លោកអ្នក ដែលរួមមានដូចខាងក្រោម៖

- **ទម្រង់លើកលែងពន្ធលក់នៅទីក្រុង Pennsylvania**
- **ការជូនដំណឹងរបស់អ្នកលក់—**ការជូនដំណឹងដែលលោកអ្នកបានផ្តល់ឲ្យអ្នកចែកចាយដែលលោកអ្នកលក់ ភេសជ្ជៈផ្អែមនៅកន្លែងលក់រាយក្នុងទីក្រុង Philadelphia (អាចជាទម្រង់លើកលែងពន្ធលក់នៅទីក្រុង Pennsylvania)។
- **ការបញ្ជាក់—**ការឆ្លើយតបដែលលោកអ្នកបានទទួលពីអ្នកចែកចាយរបស់លោកអ្នកដែលបញ្ជាក់ថាពួកគេនឹង ដាក់ពន្ធលើការទិញរបស់លោកអ្នកពីពួកគេ។
- **វិក្កយប័ត្រ—**ត្រូវបញ្ជាក់ថាពន្ធភេសជ្ជៈ Philly ត្រូវបានបង់នៅលើប្រតិបត្តិការ។

### ឯកសារត្រឹមត្រូវ

ប្រសិនបើលោកអ្នកមានឯកសារបង្ហាញថា ពន្ធភេសជ្ជៈត្រូវបានបង់លើអ្វីដែលលោកអ្នក បានជាវ—ហើយឯកសារទាំងនោះត្រូវបានចាត់ទុកថាត្រឹមត្រូវ—ឬលោកអ្នកបានចុះបញ្ជីឬអ្នកលក់ពិសេស **លោកអ្នកមានគ្រប់ទាំងអស់!** **ការស៊ើបអង្កេតចប់ត្រឹមនេះ។**

### ឯកសារមិនត្រឹមត្រូវ ឬ គ្មានឯកសារ

ប្រសិនបើលោកអ្នកមិនមានឯកសារដែលត្រូវបានទាមទារ**ឬមានឯកសារមិនត្រឹមត្រូវ ការពិនិត្យ** អនុវត្តពន្ធភេសជ្ជៈរបស់លោកអ្នកនឹងត្រូវបានកំណត់ពេលវេលាឡើងវិញហើយលោកអ្នកនឹងទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរសម្រាប់ការតាមដានចុះពិនិត្យ។ នៅពេលយើងចុះពិនិត្យលោកអ្នក **លើកទីពីរ** លោកអ្នក **ត្រូវតែអនុវត្តតាមពន្ធភេសជ្ជៈ** ឬយើងនឹងចាត់វិធានការណ៍ **តាមច្បាប់។**

## ការអនុវត្តច្បាប់

ប្រសិនបើករណីរបស់លោកអ្នកឈានដល់ដំណាក់កាលអនុវត្តច្បាប់ នាយកដ្ឋានច្បាប់នឹងផ្ញើជូនលោកអ្នកនូវការជូនដំណឹងផ្លូវការ នៅចំណុចណាមួយដែលលោកអ្នកត្រូវមានសកម្មភាពមួយក្នុងចំណោមពីរ៖

- បង្កើតកំណត់ត្រាត្រឹមត្រូវ។
- ចុះបញ្ជីពន្ធ រៀបចំរបាយការណ៍ពន្ធដែលខ្វះ និង បង់ពន្ធភេសជ្ជៈ។

ប្រសិនបើលោកអ្នកមិនអនុវត្តតាមច្បាប់ទេ លោកអ្នកនឹងទទួលបានការវាយតម្លៃដោយពិន័យជាទឹកប្រាក់ 1,000 ដុល្លារអាមេរិក។ ប្រសិនបើអ្នកត្រូវបានរកឃើញថាមិនបានអនុវត្តតាមច្បាប់ជាលើកទីពីរក្នុងរយៈពេលពីរឆ្នាំនោះអាជ្ញាប័ណ្ណសកម្មភាពពាណិជ្ជកម្មរបស់លោកអ្នកអាចត្រូវបានដកហូតវិញ ក្នុងករណីនេះ លោកអ្នកតម្រូវឲ្យបញ្ឈប់ប្រតិបត្តិការអាជីវកម្មរបស់លោកអ្នករហូតដល់អាជ្ញាប័ណ្ណត្រូវបានអនុវត្តឡើងវិញ។

## ការចូលប្រើភាសា

សូមចូលទៅ PhillyBevTax.com/Dealers/Resources

Encuentre información en su idioma.
Trouvez des informations dans votre langue.
귀하의 언어로 정보를 찾으십시오.
Tìm thông tin bằng ngôn ngữ của bạn.
Поиск информации на вашем языке.
查找用您的語言书写的信息。
Encontre informações em seu idioma.
ស្វែងរកព័ត៌មានជាភាសារបស់អ្នក។